ស្ថានទូតជប៉ុន

ថ្ងៃទី 02 ខែ មិនា ឆ្នាំ 2001

# ពត៌មានស្តីអំពីជំនួយអភិវឌ្ឍន៍របស់ជប៉ុន

## ពិធីសម្ពោធអាគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាស្រាក្នុងខេត្តតាកែវ

បណ្តាអ្នកយកពត៌មានទាំងអស់ ត្រូវបានអញ្ជើញអោយចូលរួមដើម្បីយកពត៌មាន និង ថតរូបភាព

ថ្ងៃទី 05 ខែ មិនា ឆ្នាំ 2001 វេលាម៉ោង 08:30 នាទីព្រឹក

នៅសាលាបឋមសិក្សាសោម

(នៅក្នុងភូមិសោម ឃុំសោម ស្រុកគីរីវង្ស ខេត្តតាកែវ)

ពិធីនេះគឺដើម្បីសម្ពោធអាគារសិក្សាសាងសង់ថ្មីមួយខ្នងនៅសាលាបឋមសិក្សាស្រា ស្ថិតនៅក្នុងភូមិស្រោ ឃុំតៅ ស្រុកគីរីវង្ស ខេត្តតាកែវ ក្រោមអធិបតីភាពឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទីស្តីការគណរដ្ឋមន្ត្រី និង លោក អេហ្ស៊ី យ៉ាម៉ាម៉ូតូ (EIJI YAMAMOTO) អគ្គទីប្រឹក្សា ស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ។

ការសាងសង់អាគារសិក្សានេះត្រូវបានអនុវត្តន៏ដោយសមាគមជំនួយសាលារៀននៅកម្ពុជា (ASAC) ដែលជាអង្គការក្រៅរដ្ឋាភិបាលរបស់ជប៉ុនមួយកំពុងធ្វើការជួយដល់វិស័យអប់រំនៅកម្ពុជា ។ ដោយផ្អែកទៅលើកិច្ចសន្យាផ្តល់ជំនួយ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី 11 ខែ សីហា ឆ្នាំ 2000 រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាចំនួន US$ 26,600 តាមរយៈជំនួយឧបត្ថម្ភឥតសំណងរបស់ជប៉ុនសំរាប់គំរោងការទ្រង់ទ្រាយតូចៗ ដែលភាសាជប៉ុនហៅថា " គូសាណូណេ " ។ ជាលទ្ធផលនៃគំរោងការនេះ គេសង្ឃឹមថា កុមារា-កុមារី ដែលត្រូវអោយចូលសាលារៀនប្រមាណ 2,059 នាក់ ដែលរស់នៅក្នុងភូមិស្លា និង ភូមិក្រសាំងពុល នឹងទទួលបាននូវការសិក្សារៀនសូត្រនៅក្នុងបរិស្ថានដ៏សមរម្យ និង ប្រកបដោយសុវត្ថិភាព ។

" គូសាណូណេ " គឺជាជំនួយឧបត្ថម្ភរបស់ជប៉ុនមួយបែបដើម្បីជួយដល់គំរោងការតូចៗនៅតាមមូលដ្ឋានដែលផ្តួចផ្តើមគំនិតដោយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និង ក្នុងស្រុក ឬ ដោយអាជ្ញាធរមូលដ្ឋាន ហើយក៏ជាសសរទ្រូងមួយដ៏សំខាន់នៃជំនួយសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុននៅកម្ពុជាផងដែរ ។ ចាប់តាំងពីការផ្តើមអនុវត្តន៏ជំនួយឧបត្ថម្ភបែបនេះនៅប្រទេសកម្ពុជានៅឆ្នាំ 1992 មក " គូសាណូណេ " បានផ្តល់ទឹកប្រាក់សារុបចំនួន US$8,860,747 ហើយសំរាប់ 177 គំរោងការនៅកម្ពុជាដើម្បីជួយដល់ការខិតខំប្រឹងប្រែងស្តារ និង អភិវឌ្ឍន៍ឡើងវិញតំបន់ជនបទនៃកម្ពុជា ។

❖❖❖

ស្ថានទូតជប៉ុន លេខ 75 មហាវិថីព្រះនរោត្តម ទូរស័ព្ទ: 023.21.71.61/4 ហ្វាក់: 023.21.61.62

**E-mail Address: eojc@bigpond.com.kh**

**Official website: www.bigpond.com.kh/users/eojc/indexe.htm**